# ពពួកសត្វសមុទ្របុរាណ “គ្រីណូអ៊ីត Crinoids” អាយុរាប់លានឆ្នាំនៅកម្ពុជា

ចាប់ពីឆ្នាំ២០១៩មក ក្រុមការងារសិក្សាស្រាវជ្រាវផូស៊ីល ដោយនាយកដ្ឋានតំបន់បេតិកភណ្ឌ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ បានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវអំពីជីវចម្រុះសម័យបុរាណ នៃប្រទេសកម្ពុជា។ មកដល់ពេលនេះយើងបានចុះសិក្សាព័ត៌មានបឋម បានចំនួន២៤ទីតាំងមកហើយ និងធ្លាប់បានចុះផ្សាយក្នុងប្រព័ន្ធវេបសាយ AMS អរិយធម៌ខ្មែរ ជាបន្តបន្ទាប់ អំពីទីតាំងមួយចំនួនដែលបានសិក្សាផងដែរ។ ក្នុងអត្ថបទនេះ ខ្ញុំនឹងលើកយកពីប្រភេទសត្វមួយក្រុម ដែលហៅថាគ្រីណូអ៊ីត Crinoids ។ ពាក្យស័ព្ទមួយចំនួន គឺពិបាកនឹងរកពាក្យជាភាសាខ្មែរមកប្រើប្រាស់ ពេលខ្លះយើងយកភាសាបរទេសមកសរសេរជាខ្មែរ ហើយក៏នឹងអាចមានការលំអៀងនៃការប្រើប្រាស់ពាក្យដោយអន្ទើណាមួយជាពុំខាន។

គ្រីណូអ៊ីតជាអ្វី? Crinoids គឺជាសត្វសមុទ្រមួយក្រុម ដែលបង្កើតជាក្រុម Crinoidea ដែលជាផ្នែកមួយនៃ Phylum Echinodermata ដែលរួមបញ្ចូលទាំងក្រុមផ្កាយសមុទ្រ (Starfish), ក្រុមនេះក៏រូបរាងប្រហាក់ប្រហែលនឹងប្រភេទផ្កាយសមុទ្រ (Brittle Stars) ដែរ, ក្រុមកាំប្រមាសមុទ្រ (Sea Urchins) និងក្រុមឈ្លើងសមុទ្រ (Sea Cucumbers)។[១]

គ្រីណូអ៊ីត បានបន្តមករស់នៅរហូតដល់ពេលបច្ចុប្បន្នដែលមានប្រមាណជា៥៤០ពូជន៍។[២] សម្រាប់ក្នុងប្រទេសកម្ពុជា ខ្ញុំក៏មិនដឹងថាតើមានឬយ៉ាងណា? តែខ្ញុំយល់ថាគួរតែមាន ដោយយើងខ្វះឯកសារពីប្រទេសយើង(រូបលេខ១)។ តាមរយៈឯកសារមួយ គឺបានបង្ហាញពីប្រភេទក្រុមសត្វដែលនៅជិតស្និតនឹងក្រុមសត្វគ្រីណូអ៊ីត ដូចជាពពួកផ្កាយសមុទ្រ កាំប្រមាសមុទ្រ និងក្រុមឈ្លើងសមុទ្រដែកមានក្នុងប្រទេសកម្ពុជា(រូបលេខ២)។[៣]

ប្រវត្តិនៃការរកឃើញសំណាកផូស៊ីលគ្រីណូអ៊ីតខ្លះ ត្រូវបានគេហៅថាផ្កាលីលីសមុទ្រ។ ផូស៊ីលគ្រីណូអ៊ីតត្រូវបានរកឃើញ មានជីវិតនៅលើផែនដីកាលពីប្រមាណ ៤៥០លានឆ្នាំមុន។[៤] សត្វគ្រីណូអ៊ីត មានរូបរាងដូចជាផ្កាព្រលិតមួយដើមដែលមានផ្នែក

---

[១] https://en.wikipedia.org/wiki/Crinoid

[២] https://en.wikipedia.org/wiki/Crinoid

[៣] សៀវភៅមគ្គុទេសក៍អំពី ធនធានជលផលសមុទ្រ នៅព្រះរាជាណាចក្រកម្ពុជា, ២០០៨: ៩៦-៩៧

[៤] https://en.wikipedia.org/wiki/Crinoid

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ផ្កា ដើម និងឫស (រូបលេខ៤-៥) ខ្លះមានដើមខ្លី និងខ្លះមានដើមវែង។ គេបានរកឃើញគ្រីណូអ៊ីតខ្លះមានប្រវែងដល់ទៅ១ម៉ែត្រ។ ពួកវាជាប្រភេទសត្វដែលរស់នៅក្នុងទឹករាក់។ ថ្វីត្បិតយើងមើលទៅហាក់ដូចជារុក្ខជាតិតែការពិតពួកគ្រីណូអ៊ីត ជាសត្វអាចធ្វើដំណើរ និងហែលទឹកបាន។

នៅក្នុងប្រទេសកម្ពុជាយើងបានជួបប្រទះផូស៊ីលសត្វគ្រីណូអ៊ីត ដែលមានផ្នែកខាងក្បាលរបស់វានៅភ្នំស្វាយ ក្នុងខេត្តបន្ទាយមានជ័យ (រូបលេខ៦)។ ភ្នំស្វាយជាប្រភេទភ្នំថ្មកំបោរដែលមានអាយុកាលនៅស័កទី១ ក្នុងសម័យ Permian ( ២៥១-២៩៩លានឆ្នាំ)[៤] ភ្នំស្វាយ ជាស្ថានីយមួយដែលយើងបានរកឃើញផូស៊ីលពពួកសត្វគ្រីណូអ៊ីតច្រើនគេ។ តែភាគច្រើនរកឃើញតែបំណែកដើមរបស់ពួកវាតែប៉ុណ្ណោះ។ ពួកវាប្រហែលស្ថិតនៅក្នុងថ្ម តែយើងពុំទាន់បានសិក្សាបានលម្អិតអំពីទីតាំងនីមួយនៅឡើយ។ តាមរយៈផ្នែកដើមនៃគ្រីណូអ៊ីត (Crinoid columnal) មានលក្ខណៈមិនដូចគ្នានោះទេ និងអាចបែងចែកជាប្រភេទផ្សេងៗ។ យើងប្រទះឃើញប្រមាណ៥ប្រភេទ ឬច្រើនជាងនោះ ដោយយើងសំគាល់ទៅលើស្នាមរន្ធនៅកណ្តាល ស្នាមឆ្នូតៗនៅជុំវិញរន្ធនោះ និងទំហំនៃដើមរបស់វា សូមមើលរូបដែលថតពីភ្នំស្វាយ(រូបលេខ៦) និងគំរូខ្លះៗនៃប្រភេទគ្រីណូអ៊ីត (រូបលេខ៧-៨)។

ពពួកផូស៊ីលសត្វគ្រីណូអ៊ីតត្រូវបានយើងរកឃើញ នៅតាមស្ថានីយផូស៊ីលមួយចំនួនក្នុងប្រទេសកម្ពុចាដូចជា ខេត្តបន្ទាយមានជ័យ រកឃើញច្រើនជាងគេ ភ្នំស្វាយ (ច្រើន) ភ្នំជញ្ជាំង(ច្រើន) ភ្នំបាក់(មធ្យម) ភ្នំដូងព្រះ(តិច) ភ្នំកងវ៉ា(តិច) ភ្នំព្រះភ្នំវែង (មធ្យម)។ ខេត្តបាត់ដំបង ភ្នំសំពៅ(តិច) ភ្នំបាណន់(តិច) ភ្នំគោហា(តិច)។ ខេត្តស្ទឹងត្រែង រកឃើញនៅថ្មកំបោរ តំបន់រាមសារទន្លេមេគង្គ (តិច) ភ្នំឈ្វាក(តិច) ភ្នំចាបភ្លើង ក្នុងស្រុកថាឡាបរិវ៉ាត់។ ខេត្តកំពត ភ្នំកំពង់ត្រាច (តិច) ដែលរកឃើញក្នុងរូបភ្នំ និងអាចមាននៅទីតាំងផ្សេងៗទៀតដែលយើងមិនទាន់មានទិន្នន័យនៅឡើយ។

រួមសេចក្តីមកតាមរយៈផូស៊ីលសត្វគ្រីណូអ៊ីត ដែលរកឃើញនៅក្នុងប្រទេសកម្ពុជានេះត្រូវបានកំណត់អាយុកាលក្នុងស័កទី១ក្នុងសម័យ Permian (២៥១-២៩៩លានឆ្នាំ)។ នោះមានន័យថានាស័កទី១ ប្រទេសកម្ពុជាស្ទើរតែទាំងស្រុងស្ថិតនៅក្រោមសមុទ្រនៅឡើយ។ យើងសង្ឃឹមថានឹងមានអ្នកជំនាញខាងផូស៊ីល ដើម្បីសហការចូលរួមធ្វើការស្រាវ

[៤] General Department of Mineral Resource, 2010, Geological Map of Cambodia

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ជ្រាវឱ្យកាន់តែលម្អិតអំពីពពួកផូស៊ីលនីមួយៗ ដែលក្រុមការងារបានរកឃើញនៅតាមបណ្ដាស្ថានីយមួយចំនួនក្នុងប្រទេសកម្ពុជា។



រូបលេខ១ ប្រភេទ១នៃគ្រីណូអ៊ីតដែលមានក្នុងពេលបច្ចុប្បន្ន ប្រភព google ( ប្រទេសកម្ពុជា? )

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ២៤៖ ដកស្រង់ពីសៀវភៅមគ្គុទេសក៍អំពី ធនធានជលផល នៅក្នុងប្រទេសកម្ពុជា






រូបលេខ៧-៨៖ គ្រីណូអ៊ីត ប្រភពពី google



រូបលេខ៩៖ គ្រីណូអ៊ីត ផ្នែកក្បាល ភ្នំស្វាយខេត្តបន្ទាយមានជ័យ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ៦៖ បំណែកដើម របស់គ្រីណូអ៊ីត ភ្នំស្វាយ






រូបលេខ៧-៨៖ ប្រភព google

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័